Australian Government



# មាតាបិតា

## ពិភាក្សាអំពីជម្រើសអាជីព

2011

ក្នុងនាមជាមាតាបិតា លោកអ្នកមានតួនាទីសំខាន់ក្នុងការជួយកូនលោកអ្នកឲ្យធ្វើសេចក្តីសម្រេចចិត្តអំពីជម្រើសការអប់រំ និងអាជីព។ លោកអ្នកគួរចាប់ផ្តើមបំពេញតួនាទីនេះ ចាប់តាំងពីកូនលោកអ្នកនៅក្មេង ក្នុងខណៈដែលកូនលោកអ្នកបានឃើញលោកអ្នកនិងអ្នកដទៃដែលនៅជុំវិញខ្លួនពួកគេចូលប្រលូកក្នុងជីវភាពការងារប្រចាំថ្ងៃ។

នៅពេលពួកគេធំឡើង លោកអ្នកអាចបំពេញតួនាទីកាន់តែសំខាន់ថែមទៀតក្នុងការជួយផ្តល់យោបល់អំពីការអភិវឌ្ឍអាជីពពួកគេនិងជួយលើកទឹកចិត្តឲ្យពួកគេមានគំនិតសុទិដ្ឋិនិយម,សេចក្តីសាទរ,កំលាំងកាយចិត្ត និងគំនិតចង់ចេះចង់ដឹង។ ការប្រាស្រ័យទាក់ទងល្អរវាងលោកអ្នកនិងកូនលោកអ្នកអាចជួយឲ្យលោកអ្នកសម្រេចភារៈកិច្ចខាងលើបានល្អ។

កូនសៀវភៅនេះមានបង្ហាញលោកអ្នកអំពីវិធីដែលមានប្រយោជន៍ និងអាចអនុវត្តបានក្នុងការចូលរួមជួយរៀបចំផែនការអាជីពរបស់កូនលោកអ្នក។ កូនសៀវភៅនេះផ្តល់ព័ត៌មានថ្មីៗស្តីអំពីជម្រើសជាច្រើនដែលកូនលោកអ្នកនឹងជ្រើសរើសយក នៅពេលពួកគេបញ្ចប់ការសិក្សានៅសាលា។ កូនសៀវភៅនេះក៏ផ្តល់ព័ត៌មានអំពីធនធាន និងវិបសាយថ៍ដែលមានប្រយោជន៍ផ្សេងៗទៀតផងដែរសម្រាប់លោកអ្នកស្វែងយល់បន្ថែម។

# ចាប់ផ្តើមពិភាក្សា

សូមលោកអ្នកប្រើប្រាស់ឱកាសគ្រប់បែបយ៉ាងដើម្បីពិភាក្សាជាមួយកូនលោកអ្នកអំពីឱកាសនានាដែលមានសម្រាប់អនាគតរបស់ពួកគេ។ ក្មេងភាគច្រើនឆ្លើយតបបានល្អទៅនឹងយោបល់លោកអ្នកស្តីអំពីអាជីពរបស់ពួកគេតាមរយៈការសន្ទនាសាមញ្ញ។ ដូច្នេះលោកអ្នកត្រៀមខ្លួនឆ្លើយសំណួររបស់ពួកគេ នៅពេលពួកគេសួរអំពីជីវិតរបស់ពួកគេក្រោយពីបញ្ចប់ការសិក្សានៅសាលា។

កូនលោកអ្នកអាចចង់ដឹងពីវិធីធ្វើសេចក្តីសម្រេចចិត្តអំពីអាជីពរបស់លោកអ្នក។ សូមលោកអ្នកត្រៀមខ្លួនប្រាប់ពួកគេអំពីការងារផ្ទាល់ខ្លួន និងបទពិសោធន៍លោកអ្នក ហើយនិងផ្លូវជ្រើសរើសដែលជួយឲ្យលោកអ្នកទទួលបានអាជីពដែលលោកអ្នកកំពុងធ្វើសព្វថ្ងៃ។ ពួកគេនឹងទទួលបានផលប្រយោជន៍ពីការស្វែងយល់ពីការងារផ្សេងៗរបស់លោកអ្នក និងវិធីដែលលោកអ្នករកការងារទាំងនេះបាន ព្រមទាំងពីចំណង់ចំណូលចិត្តរបស់លោកអ្នកចំពោះការងារទាំងនេះផងដែរ។ កូនលោកអ្នកក៏អាចចង់ស្វែងយល់ពីបទពិសោធន៍របស់សមាជិកគ្រួសារផ្សេងទៀត និងមិត្តភក្តិ។ លោកអ្នកអាចស្គាល់អ្នកដែលមានការងារ ឬធ្វើការក្នុងវិស័យដែលកូនលោកអ្នកចាប់អារម្មណ៍។ លោកអ្នកអាចសាកល្បងទំនាក់ទំនងជាមួយអ្នកទាំងនោះឲ្យមកនិយាយប្រាប់កូនលោកអ្នកអំពីការងារពួកគេ ព្រមទាំងចំណុចវិជ្ជមាន និងអវិជ្ជមានរបស់វា។

សូមត្រៀមសំណួរសួរកូនលោកអ្នកផង។ សូមសួរកូនលោកអ្នកអំពីគំនិតរបស់ពួកគេក្នុងការបន្តការសិក្សាមុខវិជ្ជាផ្សេងៗ។ សូមស្វែងយល់អំពីមុខវិជ្ជាមិត្តភក្តិរបស់ពួកគេគ្រោងនឹងសិក្សា។ សូមសួរមិត្តភក្តិរបស់កូនលោកអ្នកថា តើពួកគេបានពិភាក្សាជាមួយអ្នកផ្តល់ប្រឹក្សាប្រចាំសាលាអំពីអាជីពឬទេ។ សូមសួរថា តើពួកគេដឹងពីវិធីស្វែងយល់ពីអាជីពឲ្យបានច្រើន ឬក៏ពួកគេមានបំណងចង់ចូលរួមក្នុងការដាក់តាំងពិព័រណ៍ស្តីអំពីអាជីពដែរឬទេ។ ការដាក់តាំងពិព័រណ៍នេះជាមធ្យោបាយដ៏ល្អមួយដើម្បីស្វែងយល់ពីស្ថាប័នអប់រំ និងបណ្តុះបណ្តាលនៅក្នុងតំបន់លោកអ្នករស់នៅ និងជួបជាមួយនឹងនិយោជកដែលមានសក្តានុពល។

សូមគិតពីបទពិសោធន៍កូនលោកអ្នក។ តើពួកគេបានជួយក្នុងការប្រកបរបរចិញ្ចឹមជីវិតរបស់លោកអ្នកឬទេ? តើពួកគេធ្វើកិច្ចការកំសាន្តដោយមានគំនិតច្នៃប្រឌិត ឬមានបំណិនពិសេស ឬក៏ទេពកោសល្យដែលអាចរកការងារធ្វើបានឬទេ? តើពួកគេដែលធ្វើការជាអ្នកស្ម័គ្រចិត្ត ឬធ្វើការងាររកកម្រៃក្រៅម៉ោង ឬក៏ធ្វើការយកបទពិសោធន៍ឬទេ? តើពួកគេមានអារម្មណ៍យ៉ាងណាដែរចំពោះបទពិសោធន៍ទាំងនេះ? ការរៀនសូត្រពីអ្វីដែលពួកគេមិនចង់ធ្វើមានសារៈសំខាន់ដូចជាការរៀនសូត្រពីអ្វីដែលពួកគេចង់ធ្វើដែរ។ ទោះបីជាពួកគេមិនពេញចិត្តនឹងបទពិសោធន៍របស់ពួកគេក្តី ក៏គួរពិភាក្សាអំពីហេតុផលដែលធ្វើឲ្យពួកគេមិនសប្បាយចិត្តដែរ។

លោកអ្នកអាចពិភាក្សាអំពីបទពិសោធន៍កូនលោកអ្នកឲ្យបានច្រើនជាងនេះដើម្បីជួយពួកគេឲ្យយល់បានច្បាស់លាស់អំពីចំណាប់អារម្មណ៍, ចំណង់ចំណូលចិត្ត និងការមិនចូលចិត្ត, ចំណុចខ្លាំង និងចំណុចខ្សោយ, បំណិនរបស់ពួកគេ និងចំណុចដែលមានសារៈសំខាន់ចំពោះពួកគេ។ សូមពិភាក្សាអំពីចំណុចសំខាន់នៃបំណិនក្នុងការបំពេញការងារ (សូមអានបញ្ជីរាយប្រភេទបំណិនចាំបាច់ក្នុងការបំពេញការងារនៅទំព័រទី 6)។

ហើយពិសេសជាងនេះទៅទៀត សូមលោកអ្នកជួយគាំទ្រ និងលើកទឹកចិត្តដល់កូនលោកអ្នក។ សូមរក្សាគំនិតវិជ្ជមានទៅលើគំនិតពួកគេ និងឱកាសស្វែងរកមាគាអាជីពដែលពួកគេពេញចិត្ត។ សូមបង្ហាញឲ្យកូនលោកអ្នក មើលឃើញថា លោកអ្នកមានជំនឿថា ពួកគេជាអ្នកមានសមត្ថភាព និងប្រាជ្ញាវាងវៃ។ ឥទ្ធិពលមាតាបិតារបៀបនេះអាចជួយបង្កើនជំនឿចិត្ត, ភាពចាស់ទុំ និងសេចក្តីប្រាថ្នាចង់ទទួលជោគជ័យក្នុងអាជីពរបស់កូនលោកអ្នក។






# បទពិសោធន៍ក្នុងជីវិត

## រឿងពិតរបស់យុវជនម្នាក់

កាលពីខ្ញុំរៀននៅសាលាបឋមសិក្សា ខ្ញុំចាប់ផ្តើមគេចមិនចូលរៀន។ ខ្ញុំចំណាយពេលជាច្រើនថ្ងៃលេងនៅតំបន់ជិតខាងខ្ញុំ។ ក្រោយមកខ្ញុំចាប់ផ្តើមឆ្លាក់អក្សរ និងគូរគំនូរនៅលើជញ្ជាំង (graffiti) និងចុះហត្ថលេខាខ្ញុំនៅផ្ទាំងអក្សរ និងគំនូរនានានៅក្នុងសង្កាត់ និងតំបន់ជាច្រើនក្នុងក្រុងខ្ញុំរស់នៅ។ នៅចុងបញ្ចប់ ខ្ញុំបានបោះបង់ការសិក្សាទាំងស្រុងតែម្តង។

ខ្ញុំដឹងច្បាស់ថា អ្នកគ្រប់គ្នាគិតថា ខ្ញុំមិនអាចមានសមត្ថភាពធ្វើអ្វីបានទេ។ ឪពុក និងម្តាយខ្ញុំមានការមិនពេញចិត្តនឹងអាកប្បកិរិយាខ្ញុំជាខ្លាំង ប៉ុន្តែពួកគាត់ជានិច្ចកាលគាំទ្រ និងលើកទឹកចិត្តខ្ញុំឲ្យស្វែងយល់ពីខ្លួនខ្ញុំ។ ម្តាយខ្ញុំដែលមានជំនាញខាងសិល្បៈ គឺជាអ្នកទីមួយដែលយល់ថា សិល្បៈគំនូរ និងការថតរូបប្រាកដជាធ្វើឲ្យខ្ញុំមានចំណាប់អារម្មណ៍ និងប្រាប់ផ្លូវដល់ខ្ញុំឲ្យប្រើប្រាស់បំណិន និងកំលាំងកាយចិត្តរបស់ខ្ញុំ។ រូបគាត់និងឪពុកខ្ញុំខិតខំធ្វើការរួមគ្នាដើម្បីបង្កើតឱកាសឲ្យខ្ញុំយល់ដឹងពីខ្លួនខ្ញុំបានច្បាស់និងយល់ថាតើខ្ញុំអាចឈានចាប់យកអាជីពក្នុងវិស័យសិល្បៈគំនូរដោយរបៀបណា។ ខ្ញុំនឹងបញ្ចប់បរិញ្ញាប័ត្រខាងវិចិត្រសិល្បៈនៅឆ្នាំក្រោយ។ ខ្ញុំអាចបញ្ចប់ការសិក្សាឆាប់ជាងនេះ តែខ្ញុំធ្វើការងារពីរកន្លែងដើម្បីរកប្រាក់ចំណូល។ ខ្ញុំសូមថ្លែងអំណរគុណដល់ឪពុកម្តាយខ្ញុំដែលជាអ្នកតាមជួយគាំទ្រខ្ញុំជានិច្ច។

# ជម្រើសនានា

មានមាគ៌ាជាច្រើនដែលអាចឈានទៅចាប់យកអាជីពដែលខ្លួនពេញចិត្ត។ ជម្រើសដែលពេញនិយមជាងគេមាន៖

បញ្ចប់ការហ្វឹកហាត់ការងារ ឬក៏ការសិក្សាបន្ត

- ធ្វើកម្មសិក្សា
- សិក្សានៅតាមគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេស (TAFE)
- សិក្សានៅសាកលវិទ្យាល័យ
- ផ្អាកការសិក្សាមួយឆ្នាំដើម្បីរកប្រាក់ចំណូល, ធ្វើការស្ម័គ្រចិត្ត និង/ឬ ធ្វើដំណើរកំសាន្ត
- ចាប់ធ្វើជំនួញ
- ស្វែងរកការងារធ្វើ។

ចំណុចដែលប្រសើរនោះគឺការជ្រើសរើសអាជីព ឬការសិក្សាក្នុងពេលបច្ចុប្បន្ននេះមិនកាត់បន្ថយជម្រើសរបស់មនុស្សយើងនៅពេលអនាគតទេ។ មនុស្សយើងសម័យនេះលែងធ្វើការងារដដែល ឬធ្វើការនៅក្នុងវិស័យតែមួយអស់មួយជីវិតទៀតហើយ។

ភាពបត់បែននេះផ្តល់ភាពងាយស្រួល និងជាប្រភពនៃសេចក្តីពេញចិត្តនឹងការងារទាំងស្រុង។ ដើម្បីទាញយកផលប្រយោជន៍ឲ្យបានច្រើនបំផុតពីសេរីភាពនៃជម្រើសនេះ មនុស្សគ្រប់គ្នាគួរផ្តល់អាទិភាពដល់ការសិក្សា និងបន្តការសិក្សា។ ជាការពិត ដើម្បីពង្រីកជម្រើសការងារពួកគេ មនុស្សពេញវ័យជាច្រើនតែងតែត្រឡប់ចូលរៀនតាមគ្រឹះស្ថានអប់រំវិញដើម្បីបង្កើនចំណេះដឹង និងសញ្ញាប័ត្ររបស់ខ្លួន។

ការសិក្សាស្រាវជ្រាវបង្ហាញឲ្យដឹងថា អ្នកដែលទទួលការអប់រំដល់ថ្នាក់ទី ១២ ឬការអប់រំមានតម្លៃស្មើអាចរកការងារបានធ្វើភាគច្រើន ហើយអ្នកទាំងនោះក៏អាចទាញយកផលប្រយោជន៍ពីជម្រើសអាជីពថ្មីៗ ប្រសិនបើពួកគេបន្តការសិក្សា។ ក្នុងពេលបច្ចុប្បន្ននេះ មានមនុស្សជាច្រើនកំពុងធ្វើការងារថ្មី ដែលពុំដែលមានពីសម័យមុន នៅពេលពួកគេបានចូលប្រឡូកក្នុងការងារជាលើកដំបូង។

**អាជីព** – ការងារមានកម្រៃ និងគ្មានកម្រៃ, ការសិក្សា និងតួនាទីក្នុងជីវិតដែលលោកអ្នកប្រតិបត្តិក្នុងជីវិតរស់នៅរបស់លោកអ្នក។

**ការងារ** – មុខតំណែងដែលលោកអ្នកប្រើប្រាស់សម្រាប់បំពេញកិច្ចការដើម្បីរកប្រាក់ចំណូល។

ដូច្នេះសូមពិនិត្យឲ្យបានច្បាស់អំពីមាគ៌ាដែលពេញនិយមជាងគេ។

## ការហ្វឹកហាត់ការងារ និងការសិក្សាបន្ត

**ការបណ្តុះបណ្តាលនិងអប់រំវិជ្ជាជីវៈ(Vocational Education and Training - VET)** នៅតាមសាលារៀនអនុញ្ញាតឲ្យសិស្សអាចសិក្សាវិជ្ជាជីវៈនិងមុខវិជ្ជាផ្សេងទៀតក្នុងពេលជាមួយគ្នា។ នេះជាមធ្យោបាយដ៏ល្អមួយសម្រាប់យុវជនសិក្សាអំពីអាជីពដែលអាចចាប់យកបាន និងទទួលបានបំណិនដែលមានប្រយោជន៍ ក្នុងខណៈដែលពួកគេបើកចំហជម្រើសពួកគេដើម្បីចូលរៀនវគ្គបណ្តុះបណ្តាល និង/ឬក៏បន្តការសិក្សានៅពេលអនាគត។

**កម្មវិធីផ្តល់ការហ្វឹកហាត់ការងារប្រទេសអូស្ត្រាលី (Australian Apprenticeships)** ផ្តល់បទពិសោធន៍ការងារជាក់ស្តែង និងការបណ្តុះបណ្តាលមុខជំនាញជាង ៥០០ ប្រភេទ។ សិស្សទទួលការហ្វឹកហាត់ការងារទទួលបាននូវបំណិនថ្មីៗ បង្កើតបានចំណុចផ្តើមដ៏ល្អដើម្បីឈានទៅចាប់យកអាជីពគួរឲ្យចាប់អារម្មណ៍ ហើយអាចរកប្រាក់កម្រៃបានខ្លះផងក្នុងពេលតែមួយ។

**កម្មវិធីផ្តល់ការហ្វឹកហាត់ការងារនៅតាមសាលារៀនប្រទេសអូស្ត្រាលី (Australian School-based Apprenticeships)** ផ្តល់ដល់យុវជននូវចំណុចចាប់ផ្តើមនៃអាជីពដែលពួកគេបានជ្រើសរើស។ សិស្សរកប្រាក់កម្រៃបាននៅពេលពួកគេរៀនផង និងធ្វើការផង។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទស្សនាវិបសាយថ៍៖
**www.australianapprenticeships.gov.au**

**មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ (Trade Training Centres)** ត្រូវបានបង្កើតឡើងនៅតាមសាលារៀននៅទូទាំងប្រទេសអូស្ត្រាលី ដើម្បីជួយឲ្យសិស្សអាចទទួលបាននូវការសិក្សាទាក់ទងនឹងវិជ្ជាជីវៈដែលមានគុណភាពខ្ពស់បំផុត និងសិក្សានៅមជ្ឈមណ្ឌលបណ្តុះបណ្តាលដែលឆ្លើយតបនឹងស្តង់ដារការងារតាមវិស័យនីមួយៗ។

## ធ្វើកម្មសិក្សា

កម្មសិក្សាអាចជាជម្រើសដ៏ល្អមួយសម្រាប់ចាប់ផ្តើមអាជីព ជាពិសេសនៅក្នុងមុខជំនាញដូចជាហិរញ្ញវត្ថុ, វិស្វកម្ម និងសារព័ត៌មាន។ ជាទូទៅសិស្សកម្មសិក្សាទទួលបានទាំងបទពិសោធន៍ការងារ និងការគាំទ្រផ្នែកថវិកាឲ្យតែពួកគេធ្វើការផង និងសិក្សាផងរយៈពេលពីរបីឆ្នាំ។ សម្រាប់ព័ត៌មានស្តីពីកម្មសិក្សាជាក់លាក់សូមអានជំពូកស្តីអំពីការណ៍ពិតនៅវិបសាយថ៍ **myfuture.edu.au**។ សូមចុចទៅលើប្រាក់ឧបត្ថម្ភ (Awards) និងអាហាររូបករណ៍ (Scholarships) ហើយបន្ទាប់មកស្វែងរកមើលពាក្យកម្មសិក្សា (Cadetships)។

គ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ និងសាលាបណ្តុះបណ្តាលផ្សេងទៀតផ្តល់វគ្គសិក្សាជាច្រើនដែលទាក់ទងនឹងការងារ និងមានការអនុវត្តជាក់ស្តែងនៅទូទាំងប្រទេសអូស្ត្រាលី។ សិស្សអាចទទួលសញ្ញាប័ត្រដែលទទួលស្គាល់ទូទាំងប្រទេសតាមមុខវិជ្ជាផ្សេងៗ ដូចជា អាកាសចរណ៍, ការថែទាំមនុស្សចាស់, បច្ចេកវិជ្ជាខាងព្យាបាលបេះដូង, សេវាកម្មថែទាំកូនក្មេង, ជាងជួសជុលឡាន, ផែនដីវិទ្យា, អ៊ុតសក់, ជាងជួសជុលលូ, ការថែទាំអ្នកជំងឺ និងមុខវិជ្ជាជាច្រើនទៀត។

សម្រាប់ព័ត៌មានបន្ថែមសូមចូលទស្សនាវិបសាយថ៍
**www.training.com.au** ឬអញ្ជើញទៅ TAFE ប្រាំតំបន់លោកអ្នក។ TAFE ភាគច្រើនមានសេវាផ្តល់ប្រឹក្សាខាងអាជីព។

**ការងារ** – ចង្កោមសកម្មភាពដោយមានលទ្ធផលគ្រោងទុក ហើយអាចរាប់បញ្ចូលទាំងការមើលថែកូនចៅ ឬការងារស្ម័គ្រចិត្ត ក៏ដូចជាការងារមានកម្រៃដែរ។

## សាកលវិទ្យាល័យ

សិស្សចំនួនប្រហែលជា ៤០ ភាគរយចូលរៀននៅសាកលវិទ្យាល័យតែម្តង បន្ទាប់ពីរៀនចប់នៅសាលាមធ្យមសិក្សា។ ការចូលរៀននៅសាកលវិទ្យាល័យនេះជាជំហានដ៏ធំមួយសម្រាប់ពួកគេដែលជាញឹកញាប់មានន័យថាជាការចាកចេញពីផ្ទះសម្បែងរបស់ខ្លួន។ សិស្សចាំបាច់ត្រូវស្វែងយល់ពីវគ្គសិក្សាដែលមាននៅតាមសាកលវិទ្យាល័យ និងទីកន្លែងបង្រៀនវគ្គសិក្សាទាំងនេះ ហើយនិងល័ក្ខខ័ណ្ឌចាំបាច់សម្រាប់ចូលរៀនវគ្គសិក្សាទាំងនេះ។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទស្សនាវិបសាយថ៍៖
**www.goingtouni.gov.au**

## ឆ្នាំផ្អាកការសិក្សា

សិស្សមួយចំនួនជ្រើសរើសយកការផ្អាកការសិក្សារយៈពេលមួយឆ្នាំបន្ទាប់ពីបញ្ចប់ការសិក្សានៅសាលាមធ្យមសិក្សា មុនពេលពួកគេបន្តការសិក្សាឬការបណ្តុះបណ្តាលបន្ថែម។ ឆ្នាំផ្អាកការសិក្សានេះផ្តល់ដល់ពួកគេនូវឱកាសធ្វើដំណើរកំសាន្ត, រៀនភាសា, លេងកីឡា ឬធ្វើកិច្ចការកំសាន្តដែលពួកគេចូលចិត្ត, រកប្រាក់ចំណូល, រៀនបំណិនថ្មីៗ ធ្វើការងារស្ម័គ្រចិត្ត ឬក៏ស្វែងយល់ពីអ្វីដែលពួកគេមានបំណងចង់ធ្វើនៅពេលអនាគត។

អង្គការសហគមន៍ជាច្រើនត្រូវការអ្នកស្ម័គ្រចិត្ត ហើយសិស្សអាចទទួលបាននូវបំណិនថ្មីៗ និងបទពិសោធន៍ការងារដ៏រឹងមាំ ប្រសិនបើពួកគេចំណាយពេលផ្អាកការសិក្សាមួយឆ្នាំនេះធ្វើការស្ម័គ្រចិត្តឲ្យអង្គការទាំងនេះ។

ដើម្បីស្វែងរកការងារស្ម័គ្រចិត្តនៅក្នុងតំបន់លោកអ្នករស់នៅសូមចូលទស្សនាវិបសាយថ៍៖ **www.govolunteer.com.au**

កងកម្លាំងយោធាអូស្ត្រាលី (Australian Defence Force) មានផ្តល់កម្មវិធីសម្រាប់សិស្សផ្អាកការសិក្សាមួយឆ្នាំដែរសម្រាប់អ្នកដែលចង់យល់ដឹងបន្ថែមអំពីរបៀបធ្វើប្រតិបត្តិការរបស់កងទ័ពជើងគោក និងជើងទឹក។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទស្សនាវិបសាយថ៍៖
**www.defencejobs.gov.au/education/gapYear**

## ចាប់ធ្វើជំនួញ

យុវជនដែលមានគំនិតច្នៃប្រឌិត ជួនកាលអាចចាប់ផ្តើមអាជីពដោយការចាប់ធ្វើជំនួញ។ រដ្ឋាភិបាលមានផ្តល់កម្មវិធី និងការបណ្តុះបណ្តាលដែលអាចជួយពួកគេឲ្យអភិវឌ្ឍគំនិតច្នៃប្រឌិត និងបង្កើនបំណិនធ្វើជំនួញរបស់ពួកគេ។

សម្រាប់ព័ត៌មានដើម្បីជួយកូនលោកអ្នកឲ្យចាប់ធ្វើជំនួញរបស់ពួកគេ សូមចូលទស្សនាវិបសាយថ៍៖ **www.business.gov.au** និង **www.enya.org.au**

## ស្វែងរកការងារធ្វើ

សិស្សមួយចំនួនជ្រើសរើសរកការងារធ្វើតែម្តង បន្ទាប់ពីបញ្ចប់ការសិក្សានៅមធ្យមសិក្សា។ ការស្វែងរកការងារដំបូងនេះអាចមានលក្ខណៈងាយស្រួល ប្រសិនបើសិស្សដែលស្វែងរកការងារយល់ដឹងបានច្រើនពីទីផ្សារពលកម្ម, បំណិនដែលទីផ្សារត្រូវការ, សេវាកម្មផ្សេងៗ, មុខរបរ, ប្រាក់ចំណូល និងទស្សនៈវិស័យការងារ។ សូមចងចាំថា ការងារជាច្រើនមិនបានផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយទេ ដូច្នេះការផ្សព្វផ្សាយពីមាត់មួយទៅមាត់មួយ និងការយល់ដឹងពីតំបន់រស់នៅបានច្បាស់ អាចជួយយ៉ាងច្រើនដល់យុវជនឲ្យរកការងារបានធ្វើ។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទស្សនាវិបសាយថ៍៖
**www.joboutlook.gov.au**

**មុខរបរ** – ការងារមានលក្ខណៈប្រហាក់ប្រហែលគ្នាដែលអាចរកបាននៅតាមវិស័យ និងអង្គការផ្សេងៗគ្នា។

# កំណើនការងារប្រទេសអូស្ត្រាលី

សេដ្ឋវិទូរំពឹងថាមានកំណើនការងារយ៉ាងច្រើននៅក្នុងវិស័យសុខាភិបាល និងសង្គមកិច្ច, ការអប់រំ និងបណ្តុះបណ្តាល ហើយនិងកសិកម្ម, រុក្ខាប្រមាញ់ និងនេសាទក្នុងរយៈពេលពីរបីទៅបួនឆ្នាំខាងមុខ។

សេដ្ឋវិទូក៏រំពឹងទុកផងដែរថា នឹងមានកំណើនការងារបង្គួរនៅគ្រប់វិស័យដូចជាសិល្បៈ និងសេវាកម្មកំសាន្ត, សេវាបម្រើម្ហូបអាហារ និងការស្នាក់នៅ, សេវាកម្មបច្ចេកវិជ្ជា និងវិទ្យាសាស្ត្រ, ដឹកជញ្ជូន, ប្រៃសណីយ៍ និងផ្គត់ផ្គង់ទំនិញ, អាជីវកម្មលក់រាយ, អគ្គីសនី, ឧស្ម័ន, ទឹក និងសេវាកម្មសម្អាតបរិស្ថាន និងសេវាកម្មរដ្ឋបាលនិងសេវាកម្មគាំទ្រ។

# ច្បាប់ស្តីអំពីការសិក្សា

ច្បាប់ប្រទេសអូស្ត្រាលីចែងថា យុវជនទាំងអស់ត្រូវតែសិក្សានៅសាលា (ឬកម្មវិធីសមមូលដែលមានការទទួលស្គាល់ជាផ្លូវការ) រហូតដល់ចប់ថ្នាក់ទី១០ ។ បន្ទាប់ពីនេះ ពួកគេត្រូវទទួលការអប់រំការបណ្តុះបណ្តាល និង/ឬការងារពេញម៉ោង (យ៉ាងហោចណាស់ ២៥ ម៉ោងក្នុងមួយសប្តាហ៍) រហូតដល់ពួកគេអាយុ១៧ឆ្នាំ។

ល័ក្ខខ័ណ្ឌចាំបាច់នេះដាក់ដោយកម្មវិធីកិច្ចសន្យាជាមួយយុវជនអូស្ត្រាលី (Compact with Young Australians) ដែលទទួលស្គាល់ទូទាំងប្រទេស។
សូមអានបន្ថែមអំពីកិច្ចសន្យានេះនៅលើវិបសាយថ៍៖
www.deewr.gov.au/compactwithyoungaustralians

# ធនធានផែនការកម្មនៅតាមគេហទំព័រសំខាន់ៗ

មានធនធាននៅតាមគេហទំព័របំនួនបួនសំខាន់ៗដែលអាចជួយលោកអ្នក និងកូនលោកអ្នកឲ្យយល់អំពីជម្រើសនិងមាគ៌ាអាជីពដែលមាននៅប្រទេសអូស្ត្រាលីបច្ចុប្បន្ន។ សូមចូលទស្សនាវិបសាយថ៍ទាំងនេះរួមគ្នា ឬដាច់ដោយឡែកពីគ្នា ហើយសូមឆ្លៀតពេលពិភាក្សាជម្រើស និងឱកាសដែលមានរៀបរាប់នៅតាមគេហទំព័រទាំងនេះ។

## ផ្ទាំងក្រដាសព័ត៌មានដែលជួយឲ្យយុវជនរកការងារឲ្យចំគោលដៅ (Bullseye Posters)

ការប្រើប្រាស់ Bullseye posters ជាមធ្យោបាយដ៏ល្អមួយសម្រាប់លោកអ្នកពិភាក្សាជាមួយកូនលោកអ្នកអំពីមុខវិជ្ជាពួកគេចូលចិត្ត និងរៀនពូកែ ហើយនិងការងារដែលទាក់ទងនឹងមុខវិជ្ជាទាំងនេះ។ ផ្ទាំងក្រដាសព័ត៌មានទាំងនេះផ្តល់ព័ត៌មានអំពីមុខវិជ្ជាសិក្សាជាង ៣០ ផ្សេងៗគ្នា ហើយនិងរាយបញ្ជីឈ្មោះមុខរបររាប់រយដែលទាក់ទងនឹងមុខវិជ្ជានីមួយៗ។ រដ្ឋាភិបាលអូស្ត្រាលី (Australian Government) ផលិតផ្ទាំងក្រដាសព័ត៌មាន និងដាក់ផ្សព្វផ្សាយដោយមិនគិតថ្លៃនៅលើវិបសាយថ៍
www.deewr.gov.au/bullseye

## វិបសាយថ៍ផ្តល់ព័ត៌មានអំពីការងារ (Job Guide)

Job Guide មានព័ត៌មានលំអិតអំពីមុខរបរជាង ៥០០មុខ។ ជាពិសេស វិបសាយថ៍នេះពន្យល់អំពីមាគ៌ាអប់រំ និងបណ្តុះបណ្តាលដែលអាចឈានទៅចាប់យកការងារនីមួយៗ។ ព័ត៌មាននេះអាចជួយយុវជនសម្រេចចិត្តចាប់យកការងារដែលសមស្របសម្រាប់ពួកគេ។ រដ្ឋាភិបាលផលិត Job Guide រាល់ឆ្នាំ និងចែកចាយដល់សិស្សថ្នាក់ទី ១០ ទាំងអស់ដោយមិនគិតថ្លៃ។ លោកអ្នកអាចមើលព័ត៌មានទាំងនេះបានតាមរយៈទូរស័ព្ទដៃលោកអ្នក និងតាមវិបសាយថ៍
www.jobguide.deewr.gov.au

## វិបសាយថ៍ផ្តល់ព័ត៌មានអំពីជំហានបន្តសម្រាប់សិស្សថ្នាក់ទី១២ (Year 12 – what next?)

វិបសាយថ៍នេះ ជួយសិស្សថ្នាក់ទី ១២ រៀបចំផែនការជីវិតពួកគេបន្ទាប់ពីបញ្ចប់ការសិក្សានៅមធ្យមសិក្សា។ វិបសាយថ៍នេះផ្តល់ការពន្យល់លំអិតអំពីជម្រើសនានា ដូចជាការហ្វឹកហាត់ការងារ TAFE សាកលវិទ្យាល័យ, ការងារមានកម្រៃ, ការងារស្ម័គ្រចិត្ត និងការចាប់ធ្វើជំនួញខ្នាតតូច។ វិបសាយថ៍នេះ ក៏បង្ហាញអំពីទីកន្លែងផ្តល់ការងារ និងបំណិនដែលទីផ្សារការងារត្រូវការ។ សូមចូលទស្សនាវិបសាយថ៍ www.year12whatnext.gov.au

## វិបសាយថ៍អនាគតរបស់ខ្ញុំ (myfuture)

វិបសាយថ៍ myfuture គឺជាមជ្ឈមណ្ឌលផ្តល់ព័ត៌មានអំពីអាជីព។ វិបសាយថ៍នេះគឺជាធនធានដែលមានអន្តរកម្មដោយមានឧបករណ៍ និងព័ត៌មានដែលអនុញ្ញាតឲ្យសិស្សអាចស្រាវជ្រាវពីមាគ៌ា និងឱកាសអាជីព។ វិបសាយថ៍នេះផ្តល់ព័ត៌មានល្អិតល្អន់អំពីមុខរបរ, វគ្គសិក្សា, ទីផ្សារពលកម្មរដ្ឋ, គន្លឹះរកការងារធ្វើ និងព័ត៌មានជាច្រើនទៀត។ ជំពូកសម្រាប់មាតាបិតាសិស្ស មានផ្តល់ប្រឹក្សាពីរបៀបដែលលោកអ្នកអាចគាំទ្រ និងលើកទឹកចិត្តកូនលោកអ្នកក្នុងខណៈដែលពួកគេធ្វើផែនការអនាគតរបស់ពួកគេ។ សូមចូលទស្សនាវិបសាយថ៍ www.myfuture.edu.au

# មន្ទីរសង្គមកិច្ច (Centrelink)

The Australian Government តាមរយៈ Centrelink ផ្តល់ការគាំទ្រផ្នែកថវិកា និងជំនួយក្នុងការរកអាជីពដល់យុវជន ដែលកំពុងសិក្សា ឬទទួលការបណ្តុះបណ្តាល ឬ Australian Apprenticeship ឬអ្នកដែលកំពុងរកការងារធ្វើ។

**បំណិនមានសារៈសំខាន់** – និយោជកតែងតែសម្លឹងរកបំណិនបន្ថែមពីនិយោជិតរបស់ពួកគេ។ ការសម្លឹងរកបែបនេះទាមទារឲ្យនិយោជិតគ្រប់រូបមានបំណិនផ្សេងទៀតក្រៅអំពីបំណិនបច្ចេកទេសដែលត្រូវការសម្រាប់បំពេញការងារ ហើយនិងដាក់បញ្ចូលនូវចំណុចពិសេសដែលគេហៅថា "បំណិនក្នុងការបំពេញការងារ"។

និយោជកបានប្រាប់យើងអំពីបំណិនបំពេញការងារចំនួនប្រាំបីដែលត្រូវការខ្លាំងជាងគេ។

បំណិនទាំងនេះមាន - ការប្រាស្រ័យទាក់ទង, ការងារជាក្រុម, ការដោះស្រាយបញ្ហា, ការផ្តួចផ្តើមគំនិត និងគំនិតច្នៃប្រឌិត, ផែនការកម្ម និងការរៀបចំ, ការគ្រប់គ្រងខ្លួនឯង, ការរៀនសូត្រ និងបច្ចេកវិទ្យា។

## ការគាំទ្រផ្នែកថវិកា

ការគាំទ្រផ្នែកថវិកាមានតាមរយៈកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភយុវជនដែលកំពុងសិក្សា, ហ្វឹកហាត់ការងារ, ទទួលការបណ្តុះបណ្តាល ឬរកការងារធ្វើ (Youth Allowance) កម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភយុវជនដែលមានអាយុចាប់ពី ២៥ឡើងដែលកំពុងរៀន ឬហ្វឹកហាត់ការងារពេញម៉ោង (Austudy) កម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភយុវជនជនជាតិដើមដែលកំពុងសិក្សា ឬហ្វឹកហាត់ការងារ (ABSTUDY) និងកម្មវិធីផ្តល់ជំនួយដល់កុមារដែលរស់នៅដាច់ឆ្ងាយពីសាលា, កុមារពិការ, កុមារដែលមានតម្រូវការថែទាំសុខភាពពិសេស( Assistance for Isolated Children)។ កម្មវិធីផ្តល់ប្រាក់កម្ចីសម្រាប់សិក្សានៅគ្រឹះស្ថានឧត្តមសិក្សា (Higher Education Loan Program - HELP) មានបញ្ចូលទាំងកម្មវិធីផ្តល់ប្រាក់កម្ចីដល់និស្សិតដែលបានទទួលកន្លែងសិក្សាដែលគាំទ្រដោយសហធនរដ្ឋឯករាជ្យ (HECS-HELP) កម្មវិធីផ្តល់ប្រាក់កម្ចីដល់និស្សិតសិក្សាបង់ថ្លៃ (FEE-HELP) កម្មវិធីផ្តល់ប្រាក់កម្ចីដល់និស្សិតត្រូវរៀនវគ្គសិក្សាខ្លះនៅបរទេស (OS-HELP) និងកម្មវិធីផ្តល់ប្រាក់កម្ចីដល់និស្សិតទទួល VET (VET FEE-HELP)។ កម្មវិធីទាំងនេះផ្តល់ប្រាក់កម្ចីដើម្បីជួយនិស្សិតមានសិទ្ធិ ដែលកំពុងសិក្សានៅគ្រឹះស្ថានឧត្តមសិក្សា និងអប់រំវិជ្ជាជីវៈបង់ថ្លៃឈ្នួលការសិក្សាពួកគេ។ មានលក្ខខ័ណ្ឌចាំបាច់ផ្សេងៗគ្នាសម្រាប់ទទួលប្រាក់កម្ចីពីកម្មវិធីទាំងនេះ។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទស្សនាវិបសាយថ៍៖
www.centrelink.gov.au

VET FEE-HELP ជួយនិស្សិតមានសិទ្ធិដែលសិក្សានៅក្នុងវគ្គអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលត្រូវបង់ថ្លៃសិក្សាពេញ ឬវគ្គសិក្សាដែលទទួលប្រាក់ឧបត្ថម្ភពីរដ្ឋមួយចំនួន ឲ្យអាចបង់ថ្លៃឈ្នួលសិក្សារបស់ពួកគេបាន។ និស្សិតមានសិទ្ធិទទួលប្រាក់កម្ចីនេះ ត្រូវរៀនវគ្គសិក្សាយកសញ្ញាប័ត្រ ដែលត្រូវបានទទួលស្គាល់ជាផ្លូវការ,សញ្ញាប័ត្រជាន់ខ្ពស់, វិញ្ញាបនប័ត្រ ឬសញ្ញាប័ត្រក្រោយឧត្តមសិក្សា ដែលបង្រៀនដោយគ្រឹះស្ថានបណ្តុះបណ្តាលដែលមានលិខិតអនុញ្ញាតត្រឹមត្រូវ (Registered Training Organisations) ឲ្យបង្រៀនវគ្គសិក្សាទាំងនេះដល់និស្សិត។

សម្រាប់ព័ត៌មានបន្ថែមដោយរាប់បញ្ចូលទាំងបញ្ជីឈ្មោះគ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាល សូមចូលទស្សនាវិបសាយថ៍ www.deewr.gov.au/vetfeehelp ឬទូរស័ព្ទមកកន្លែងផ្តល់ព័ត៌មានពីកម្មវិធី VET FEE-HELP តាមរយៈលេខ 13 38 73

## មជ្ឈមណ្ឌលផ្តល់ព័ត៌មានអំពីអាជីព (Career Information Centres)

Centrelink មាន Career Information Centres បំនួន១២ នៅទូទាំងប្រទេស។ ពលរដ្ឋអូស្ត្រាលី និងអ្នករស់នៅប្រទេសអូស្ត្រាលីអចិន្ត្រៃយ៍ទាំងអស់ដោយរាប់បញ្ចូលទាំងយុវជនដែលមានបំណងចង់ស្វែងរក ឬផ្លាស់ប្តូរការងារ មានសិទ្ធិទទួលសេវាកម្មទាំងនេះ។ បុគ្គលិកនៅទីនោះអាចជួយកូនលោកអ្នកឲ្យធ្វើសេចក្តីសម្រេចចិត្តត្រឹមត្រូវទាក់ទិននឹងជម្រើសការអប់រំ, ការបណ្តុះបណ្តាល និងការងារ។ សូមស្វែងរកទីតាំងមជ្ឈមណ្ឌលដែលនៅជិតលោកអ្នកតាមរយៈវិបសាយថ៍ www.centrelink.gov.au/internet/internet.nsf/services/career_centres.htm

# ធនធានអភិវឌ្ឍអាជីពសំខាន់ៗ

មានធនធាននៅតាមវិបសាយថ៍ពីរសំខាន់ដែលសិក្សាជាពិសេសទៅលើការអភិវឌ្ឍអាជីពនៅប្រទេសអូស្ត្រាលី។

- www.deewr.gov.au/careerdevelopment មានធនធានមិនគិតថ្លៃសម្រាប់អ្នកធ្វើការនៅក្នុងវិស័យអភិវឌ្ឍអាជីព។
- ជំពូកទី១ នៃឯកសារស្តីពីការសិក្សាអំពីការអភិវឌ្ឍអាជីពនៅប្រទេសអូស្ត្រាលី (Australian Career Development Studies) រៀបចំឡើងសម្រាប់មាតាបិតា និងអ្នកដែលមានបំណងចង់ជួយកូនជ្រើសរើសអាជីព។ សូមចូលទស្សនាវិបសាយថ៍ www.career.edu.au

# ធនធានផ្សេងទៀត

- សម្រាប់ព័ត៌មានស្តីពីកម្មវិធីផ្តល់ការហ្វឹកហាត់ការងារដល់ជនជាតិអូស្ត្រាលី (Australian Apprenticeships Access Program) សូមចូលទស្សនាវិបសាយថ៍ www.deewr.gov.au/accessprogram។ កម្មវិធីនេះជួយអ្នកដែលជួបការលំបាកក្នុងការ រកការងារជំនាញធ្វើ ដោយឲ្យពួកគេចូលសិក្សាវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈដែលទទួលស្គាល់ទូទាំងប្រទេស។
- សម្រាប់ព័ត៌មានបន្ថែមស្តីពីការហ្វឹកហាត់ការងារ និងការបន្តការសិក្សា សូមចូលទស្សនាវិបសាយថ៍ www.grouptraining.com.au
- សម្រាប់ព័ត៌មានសម្រាប់ជនជាតិដើមអូស្ត្រាលី (Indigenous Australians) ដែលមានបំណងចង់ធ្វើកម្មសិក្សា សូមចូលទស្សនាវិបសាយថ៍ www.ics.deewr.gov.au
- ដើម្បីទាញយកបញ្ជីចុះឈ្មោះលំអិតស្តីពីវគ្គសិក្សា, សញ្ញាប័ត្រ, សមត្ថភាព, កញ្ចប់បណ្តុះបណ្តាល និង Registered Training Organisations សូមចូលទស្សនាវិបសាយថ៍ www.ntis.gov.au
- ដើម្បីទាញយកទិន្នន័យលំអិតអំពីនិន្នាការការងារ និងទស្សនៈវិស័យនៃសេវាកម្មផ្តល់ការងារនៅប្រទេសអូស្ត្រាលី សូមចូលទស្សនាវិបសាយថ៍ www.skillsinfo.gov.au ។ វិបសាយថ៍នេះក៏មានផ្តល់ផងដែរនូវព័ត៌មានអំពីទីផ្សារពលកម្ម, និន្នាការការងារទំនេរ, កង្វះខាតបំណិនការងារក្នុងតំបន់ និងការអប់រំ និងការបណ្តុះបណ្តាល។

# គោលការណ៍ទាំងប្រាំនៃ
# ការអភិវឌ្ឍអាជីព

## 1. ការផ្លាស់ប្តូរមានលក្ខណៈជាប្រចាំ

សូមទទួលស្គាល់ថាពិភពនៅជុំវិញលោកអ្នកមានការប្រែប្រួលឥតឈប់ឈរ។ សូមបើកចំហចំពោះការផ្លាស់ប្តូរ និងសូមរក្សាភាពវាងវៃចាប់យកឱកាសថ្មី។

## 2. ការសិក្សាមានលក្ខណៈបន្តជានិច្ច

ខិតខំប្រឹងប្រែងអភិវឌ្ឍខ្លួនជាប់ជានិច្ច។ សូមជំរុញចិត្តឲ្យចង់អភិវឌ្ឍខ្លួនដោយរៀនបំណិនថ្មី និងអភិវឌ្ឍទេពកោសល្យថ្មី។

## 3. សូមផ្តោតលើដំណើរដ៏វែងឆ្ងាយ

សូមកុំផ្តោតលើគោលដៅតែមួយ។ សូមទទួលស្គាល់ថាដំណើរដ៏វែងឆ្ងាយនៃអាជីពរបស់លោកអ្នក គឺមានរយៈពេលពេញមួយជីវិត។ សូមស្វែងយល់ និងផ្តល់តម្លៃដល់បទពិសោធន៍នីមួយៗដែលលោកអ្នកបានទទួលនៅតាមផ្លូវដ៏វែងឆ្ងាយនេះ។

## 4. យល់ពីខ្លួនឯង ជឿជាក់លើខ្លួនឯង និងប្រតិបត្តិតាមទឹកចិត្តលោកអ្នក។

មានជំនឿដ៏មោះមុតដើម្បីសម្រេចបាននូវសមិទ្ធផល។ សូមស្វែងរកវិធីដើម្បីផ្សារភ្ជាប់ចំណាប់អារម្មណ៍របស់លោកអ្នកទៅនឹងឱកាសអាជីព។

## 5. សូមទាក់ទងសម្ព័ន្ធមិត្ត

សូមពឹងពាក់លើការគាំទ្រពីសំណាក់គ្រួសារ, មិត្តភក្តិ, អ្នកផ្តល់ប្រឹក្សា, សហការី និងអ្នកដែលមានអាយុ និងឋានៈប្រហាក់ប្រហែលគ្នារបស់លោកអ្នក។ ភាពជោគជ័យនៃអាជីព អាស្រ័យទៅលើការខិតខំប្រឹងប្រែងជាក្រុម។

B10_0814